ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៥៤៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ 201៤

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យកសិកម្ម **ខែកញ្ញា ឆ្នាំ២០១៣ - ខែកញ្ញា ឆ្នាំ២០១៤ ។**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំរបាយការណ៍ស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យកសិកម្ម **ខែកញ្ញា ឆ្នាំ២០១៣- ខែកញ្ញា ឆ្នាំ២០១៤** និងសូមផ្ញើជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូន**

- -ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- -ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- -ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០

Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
## ស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យកសិកម្ម
## ខែកញ្ញា ឆ្នាំ២០១៣ - ខែកញ្ញា ឆ្នាំ២០១៤

### I- សេចក្តីផ្តើម

អនុវត្តតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពម៉ឺងម៉ាត់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមានអង្គភាពជំនាញជាសេនាធិការបានផ្តោតលើការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយជំរុញការអនុវត្តនូវវិធានការចាំបាច់មួយចំនួនរួមមានៈ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ផលិតកម្មកសិកម្ម ការផ្តល់សេវាបច្ចេកទេសកសិកម្ម ការស្រាវជ្រាវបច្ចេកទេសកសិកម្ម ការគ្រប់គ្រងដីកសិកម្ម ការស្វះស្វែងរកប្រភពផ្តល់ឥណទានជនបទដល់កសិករ ការស្វែងរកទីផ្សារលក់ផលិតផលកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម និងការកសាងនិងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។ ទន្ទឹមនឹងនេះក៏បានគិតគូផងដែរអំពីការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងការធានាចីរភាពបរិស្ថាននិងធនធានធម្មជាតិក្នុងទិសដៅជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជូបនីយកម្មរួមទាំងការខិតខំប្រឹងប្រែងបង្កើនចំណូលថវិកាជាតិតាមផ្នែកសំខាន់ៗនីមួយៗផងដែរ។

### II- ស្ថានភាពរួម

គួរកត់សម្គាល់ថាកំណើន(%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ពី៣-៤% (២០០៩-២០១៣)។ កំណើននេះមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ហើយការប្រែប្រួលនេះក៏មានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗផងដែរ។ ដូចនេះ វិស័យកសិកម្មពឹងផ្អែកច្រើននៅឡើយលើកត្តាធម្មជាតិ ដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។ នៅឆ្នាំ២០០៩ វិស័យកសិកម្មបានកើនប្រមាណ៥,៤% ឆ្នាំ២០១២ មានកំណើនប្រហែល ៤,៣% និងនៅឆ្នាំ២០១៣ កំណើននេះបានធ្លាក់ចុះមកត្រឹម១,៧% ដោយសារផ្ទៃដីប្រមូលផលស្រូវធ្លាក់ចុះ -0,៣៨%។

ផ្នែកដំណាំមានការកើនឡើងយ៉ាងខ្លាំងដោយសមាសភាគរបស់ផ្នែកនេះមានចំនួន៥២,៩%នៅឆ្នាំ២០០៩ និងមាននិន្នាការកើនឡើងរហូតដល់៥៤,២%នៅឆ្នាំ២០១៣។ ផលិតកម្មសត្វមានសមាសភាគចូលរួមប្រមាណ១៤%នៅឆ្នាំ២០១៣។ ចំពោះសមាសភាគផ្នែកជលផលមានការប្រែប្រួលពី២៥,២%នៅឆ្នាំ២០០៩ រហូតដល់២៦,៤៥%នាឆ្នាំ២០១៣នេះ។ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើ មានការថយចុះជាបន្តបន្ទាប់បើធៀបនឹងឆ្នាំ២០០៩ ពី៦,៦% មកត្រឹមតែ៥,៥%នៅឆ្នាំ២០១៣។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការវាយតម្លៃអំពីស្ថានភាពប្រែប្រួលនៃកំណើនសម្រាប់ឆ្នាំ២០១៤នាពេលខាងមុខនេះ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក ជលផលនិងព្រៃឈើ សំដៅជំរុញលើកកម្ពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ធានាសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាននិងកំពុងស្រូបទាញនូវទុនវិនិយោគពីអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសកាន់តែច្រើនឡើងជាលំដាប់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិទោះជួបប្រទះនូវកត្តាអវិជ្ជមានខ្លះៗដំដោយ។

**III- សមិទ្ធផលនៃការបង្កើនផលិតភាព ពិពិធកម្មដំណាំ ផលិតកម្មសត្វ និង កៅស៊ូ**

ជាក់ស្តែងក្នុងឆ្នាំទី១នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមានអង្គភាពជំនាញជាសេនាធិការបានសម្រេចសមិទ្ធផលដូចតទៅ៖

**១. ការបង្កើនផលិតភាពដំណាំស្រូវ**

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដៅដើម្បីសម្រេចធ្វើយ៉ាងណាឱ្យអតិរេកស្រូវមានជាង៤លានតោន ហើយដែលអាចកែច្នៃជាអង្ករនាំចេញជាផ្លូវការយ៉ាងតិចជាង១លានតោននៅឆ្នាំ២០១៥ និងធ្វើយ៉ាងណាឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់តាមស្តង់ដារអន្តរជាតិ។ ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយខាងលើ កិច្ចការជាច្រើនត្រូវបានអនុវត្ត និងសម្រេចឱ្យបាននាពេលខាងមុខ។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ រួមទាំងមន្ទីរកសិកម្មរាជធានី-ខេត្តទាំងអស់ បានខិតខំអនុវត្តយ៉ាងសកម្មនិងខ្លាំងក្លានូវបណ្តាសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ក៏ដូចជាសកម្មភាពមួយចំនួនធំទៀត ដែលមានចែងក្នុងឯកសារគោលនយោបាយ ស្តីពី "ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ" ។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំអនុវត្តនូវសកម្មភាពជាយុទ្ធសាស្ត្រជាច្រើនដើម្បីសម្រេចទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលរួមមាន៖

ទី១- <u>ការជំរុញផលិតកម្មដំណាំស្រូវ</u>៖

ជាលទ្ធផលជាក់ស្តែង ផលិតកម្មដំណាំស្រូវអនុវត្តបាននាឆ្នាំ២០០៩សម្រេចបានចំនួន២,៧១លានហិកតា និងបានកើនដល់៣លានហិកតានាឆ្នាំ២០១៣ (កើនលើសឆ្នាំ២០០៩ប្រមាណជា១០%)។ ផ្ទៃដីអាចប្រមូលផលបានកើនពី ២,៦៧លានហិកតានាឆ្នាំ២០០៩ ដល់ជាង២,៩៦លានហិកតានាឆ្នាំ២០១៣ និងទិន្នផលមធ្យមប្រចាំឆ្នាំ២០១៣ ទទួលបានគិតទាំងប្រាំងនិងវស្សាចំនួន៣,១៦៣តោន/ហិកតា កើនលើសឆ្នាំ២០០៩ ប្រមាណ១១,៥% (ទិន្នផលស្រូវឆ្នាំ២០០៩ទទួលបានត្រឹមតែ២,៨៣តោន/ហិកតា)។ រីឯលទ្ធផលនៃការងារបង្កបង្កើនផលស្រូវសម្រាប់ឆ្នាំ២០១៤មានដូចខាងក្រោម៖

ក- ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

នៅក្នុងឆ្នាំ២០១៤នេះស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន។ ជាមួយគ្នានេះដែរ កសិករបានជួបប្រទះនូវគ្រោះធម្មជាតិ (កង្វះខាតទឹកដើមរដូវនិងនិងទឹកជំនន់ពាក់កណ្តាលរដូវ) ដែលជះឥទ្ធិពលអវិជ្ជមានដល់ការងារបង្កបង្កើនផល។ ជារួមស្ថានភាពនៃអាកាសធាតុបែបនេះបានបណ្តាលឲ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំរដូវវស្សាមួយចំនួន។ ជាមួយនឹងមូលបញ្ហាទាំងឡាយដូចបានរៀបរាប់ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំជំរុញលើការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៤និងទទួលបានលទ្ធផលដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៨៤០.៨៤៧ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន៦៦០.៣២៤ហិកតា ស្មើនឹង២៣,២៤% និងគ្រឿងយន្តចំនួន២.១៨០.៥២៣ហិកតា ស្មើនឹង៧៦,៧៦%) តិចជាងឆ្នាំមុនចំនួន៣៣៥.៦៤៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន២១២.៤៤៦ហិកតា

- ផ្ទៃដីសាបសរុបចំនួន១១២.៩៨៩ហិកតា តិចជាងឆ្នាំមុនចំនួន៤៥.៦៧៧ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៧២.០៤២ហិកតា

- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៤២០.៤៤៩ហិកតា ស្មើនឹង១០០,៣៨ភាគរយនៃផែនការ២.៤១១.២០៧ហិកតា តិចជាងឆ្នាំមុនចំនួន៨៦.០២០ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៣២.០២៤ហិកតា រួមមាន៖

• ស្រូវស្រាលចំនួន៦០៨.៧៣៧ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៧៦.៨៨៣ហិកតា) តិចជាងឆ្នាំមុនចំនួន៣៤.៩០៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៥.៤០៥ហិកតា

- ស្រូវកណ្តាលចំនួន១.១៨៦.៦៥៨ហិកតា តិចជាងឆ្នាំមុនចំនួន១៦.៦១៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៥០.៨៩២ហិកតា
- ស្រូវធ្ងន់ចំនួន៥២៨.៤៩៦ហិកតា តិចជាងឆ្នាំមុនចំនួន១៧.៦៣៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១២.៨៥៨ហិកតា
- ស្រូវចម្ការចំនួន៤៤.០៧៧ហិកតា តិចជាងឆ្នាំមុនចំនួន៣.៣៩១ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៥.៤៩២ហិកតា
- ស្រូវឡើងទឹកចំនួន៥២.៤៨១ហិកតា តិចជាងឆ្នាំមុនចំនួន១៣.៤៧៦ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៣១.៦៣៩ហិកតា។

ខ- ការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៤

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានលើផ្ទៃដីសរុបចំនួន១៨៤.៨៥៩ហិកតា តិចជាងឆ្នាំមុន២៦.៥០៣ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៦៧៤.៧៤១តោន តិចជាងឆ្នាំមុន១០៦.៦១១តោន និងទិន្នផលជាមធ្យមចំនួន៣,៦៥០តោនក្នុងមួយហិកតា លើសឆ្នាំមុន៤៧គីឡូក្រាមក្នុងមួយហិកតា។

គ- ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ

- គ្រោះខ្វះទឹក៖ ប៉ះពាល់លើផ្ទៃដីសរុបចំនួន៩៦.៩៥៣ហិកតា ក្នុងនោះសំណាបសរុបចំនួន៧.៦៤៦ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន៨៩.៣០៧ហិកតា។ សំណាបខូចខាតអស់ចំនួន១.៩១២ហិកតា សន្ទូង-ពង្រោះខូចខាតចំនួន១៧.៥៣៧ហិកតា និងស្តារសំណាបបានចំនួន២១៧ហិកតា និងសន្ទូង-ពង្រោះចំនួន៧.២៧១ហិកតា

- គ្រោះទឹកជំនន់៖ ប៉ះពាល់លើផ្ទៃដីសរុបចំនួន៧៨.២៣៦ហិកតា ក្នុងនោះសំណាបសរុបចំនួន២៣៤ហិកតា និង សន្ទូង-ពង្រោះសរុបចំនួន៧៨.០០២ហិកតា។ សំណាបខូចខាតអស់ចំនួន៧០ហិកតា និងសន្ទូង-ពង្រោះខូចខាតចំនួន២០.៨៧៣ហិកតា និងស្តារបានសន្ទូង-ពង្រោះចំនួន៤.២៨៨ហិកតា។ សូមជម្រាបជូនថា ដំណាំរួមផ្សំដែលទទួលរងនូវផលប៉ះពាល់រហូតមកដល់ពេលនេះមិនមានទិន្នន័យប្រាកដប្រជាឡើយ។ ដំណាំពោតប៉ះពាល់ចំនួន៣.៤៣២ហិកតា ក្នុងនោះខូចខាតចំនួន១.៦៨០ហិកតា ដំណាំដំឡូងមីប៉ះពាល់ចំនួន៣៣២ហិកតា ក្នុងនោះខូចខាតចំនួន៩៩ហិកតា និងបន្លែប៉ះពាល់ចំនួន៧៣៩ហិកតា ក្នុងនោះខូចខាតចំនួន១៩៩ហិកតា។

ឃ- ការងារអន្តរាគមន៍

ឆ្លើយតបទៅនឹងបញ្ហាគ្រោះធម្មជាតិខាងលើនេះ អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផលិតពូជដំណាំដើម្បីត្រៀមអន្តរាគមន៍ដូចខាងក្រោម៖

- ពូជស្រូវ:
  - ត្រៀមបម្រុងពូជស្រូវសុទ្ធល្អ (IR66 និងផលសារ) បានចំនួន២២០តោន
  - គម្រោង EFAP ពូជស្រូវបានចំនួន៤៣៤តោន
  - គម្រោង **សម្តេច ហ៊ុន សែន** ពូជស្រូវបានចំនួន៣១៥,៨៤០ តោន
- ពូជដំណាំរួមផ្សំ

ពូជបន្លែគ្រប់មុខ (ផ្ទីស ត្រសក់ គ្រប់វែង ល្ពៅ ប៉េងប៉ោះ សណ្តែកគួរ ពោតដំណើប និងពោតផ្អែម) សរុបបានចំនួន១១.៨៣០គីឡូក្រាម សម្រាប់ចែកជូនប្រជាកសិករដែលរងគ្រោះដោយទឹកជំនន់សម្រាប់យកទៅដាំដុះស្តារឡើងវិញ លើការខូចខាត។

ទី២- <u>ការជំរុញសហគមន៍ផលិតកម្មស្រូវ៖</u>

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងតម្រង់ទិសនៃការធ្វើអន្តរាគមន៍ ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្មដើម្បីផលិតក្នុងទ្រង់ទ្រាយធំ។ ជាក់ស្តែង មកពេលនេះសហគមន៍អភិវឌ្ឍន៍កសិកម្ម

សរុបទូទាំងរាជធានី ខេត្តមានចំនួន៥៥៣សហគមន៍ មានសមាជិកសរុប៥៣.៦៣៤នាក់ (ស្ត្រី៣០.១២៧៤នាក់) មានទុនសរុបចំនួន២៧.៧០៩,៥៩លានរៀល។ ការរៀបចំដើម្បីអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្ម ការពង្រឹងការងារសហគមន៍កសិកម្មក៏កំពុងត្រូវបានជំរុញផងដែរ ដោយសម្រេចបានលទ្ធផលមួយចំនួនរួមមាន៖ (១)អនុក្រឹត្យលេខ ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង(២) ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។

ទី៣- <u>ការបង្កើនផលិតភាពនិងការនាំចេញផលិតផលកសិកម្ម៖</u>

ក្រសួងបានខិតខំជំរុញ និងសម្រួលពាណិជ្ជកម្មនិងការនាំចេញ តាមរយៈសកម្មភាពភូតគាមអនាម័យ ដោយបានខិតខំពង្រឹងសមត្ថភាពបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពវាយតម្លៃនិងទប់ស្កាត់ហានិភ័យអនាម័យនិងភូតគាមអនាម័យព្រមទាំងការពង្រឹងការកសាង និងអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានាឱ្យមានប្រសិទ្ធភាព។ ជាក់ស្តែងអង្គភាពជំនាញបានធ្វើការត្រួតពិនិត្យភូតគាមអនាម័យលើកសិផលកម្ពុជាដែលនាំចេញ សរុបចំនួនជាង២លានតោន រួមមាន៖ អង្ករ២៤៩.៤៦០តោន ចំណិតដំឡូងមីក្រៀម៩៦១.២៧៥តោន ដំឡូងមីស្រស់៣១៧.៦១៣តោន ម្សៅដំឡូងមី៧.០៣៥តោន សណ្តែកសៀង១៥.៣៣៣តោន ដូងប្រេង២.៧៣៨តោន ពោត៩០.៦៨១តោន និងគ្រាប់ស្វាយចន្ទី៥១.២១៦តោន ។

ដើម្បីជំរុញកិច្ចខិតខំប្រឹងប្រែងក្នុងការនាំចេញផលិតផលកសិកម្មនៅកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចុះហត្ថលេខាលើពិធីសារជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការនាំផលិតផលពោតកម្ពុជាទៅកាន់ប្រទេសចិន និងផែនការការងារចត្តាឡីស័កសម្រាប់បើកទីផ្សារផ្លែចេក ផ្លែស្វាយ និងសណ្តែកសៀងពីកម្ពុជាទៅកាន់ប្រទេសចិន។

ជារួមការបង្កើនផលិតភាព និងការបង្កើនផលិតផលស្រូវទទួលបានជោគជ័យ ដោយសារសកម្មភាពចម្បងមួយចំនួនដូចជា៖ ការដូរពូជពីពូជស្រូវចូន់មកប្រើពូជស្រូវកណ្តាលនិងស្រូវស្រាល ការផ្ទេរបច្ចេកវិទ្យាដាំដុះដល់កសិករតាមរយៈការធ្វើស្រែបង្ហាញនិងទិវាស្រែ ដែលគាំទ្រដោយភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅតាមមូលដ្ឋាន ការធ្វើស្រែបង្ហាញអំពីប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ការប្រើប្រាស់គ្រឿងយន្តកសិកម្មសមស្រប ការបើកសាលារៀនស្រែកសិករ ការប្រើបច្ចេកទេសដំណាំគ្របដី ដើម្បីបង្កើនជីជាតិដី និងទិន្នផល ការពង្រឹងសហគមន៍កសិកម្ម និងពង្រឹងការបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍពូជស្រូវជាមួយនឹងការគ្រប់គ្រងនិងប្រើប្រាស់ជីប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការប្រើប្រាស់ពូជស្រូវសំខាន់ៗទាំង១០ពូជ ដែលបានទទួលនូវការវាយតម្លៃជាវិជ្ជមានពីសំណាក់ប្រជាកសិករ ព្រមទាំងមានការទទួលយកពីវិស័យឯកជនផងដែរ។ល។ ដែលទាំងអស់នេះជាបទពិសោធន៍ជាវិជ្ជមាននឹងជំរុញឱ្យផលិតកម្មស្រូវ មានការរីកលូតលាស់តាមការរំពឹងទុក ជាពិសេសការបំផុសចលនាកសិករឱ្យចេះធ្វើកសិកម្មចម្រុះ និងប្រែក្លាយទឹកដីដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ឱ្យទៅជាតំបន់ដែលមានពណ៌បៃតងជាអចិន្ត្រៃយ៍។ បន្ថែមពីនេះទៀតច្បាប់ស្តីពី «ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម» កំពុងត្រូវបានអនុវត្តយ៉ាងទូលំទូលាយ។

ទី៤- <u>ការបង្កើនគុណភាពផលិតផលស្រូវតាមរយៈការពិសោធន៍និងស្រាវជ្រាវ៖</u>

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអង្គភាពជំនាញបានខិតខំបង្កាត់និងផលិតពូជគ្រឹះដើម្បីចែកចាយផលិតបន្ត ព្រមទាំងបានចងក្រងនិងផ្សព្វផ្សាយពូជស្រូវ១០មុខដែលបានកំណត់ រួមទាំងវិធីសាស្ត្រសម្រិតសម្រាំងស្រូវបែបកសិករ ការកំណត់ក្រុមដី និងកម្រិតប្រើប្រាស់ជីនិងលក្ខខណ្ឌកៀក្រេបរិស្ថានដំណាំស្រូវ និងបានផ្សព្វផ្សាយជូនដល់កសិករនិងអ្នកពាក់ព័ន្ធទូទាំងប្រទេស។ ជាក់ស្តែងការងារជាច្រើនត្រូវបានអនុវត្តរួមមាន៖

- ការអភិរក្សពូជដំណាំកសិកម្ម៖ បានប្រមូលយកមករក្សាទុកបន្ថែមនូវពូជដំណាំផ្សេងៗចំនួន២៦៥សំណាក ហើយដែលជាសរុបចំនួន៦.៩២៥បញ្ជី/សំណាក នៃដំណាំចំនួន៣០ប្រភេទ

- បានបញ្ចេញពូជស្រូវធួន់ថ្មីមួយទៀតឈ្មោះ *ដំណើបស្បែមង្គល* ជូនកសិករប្រើប្រាស់
- អង្ករបស់ពូជស្រូវផ្ការំដួល ត្រូវបានចាត់ទុកជា The World's Best Rice លើកទី២ នៅទីក្រុងហុងកុង កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ កន្លងមកនេះ
- គួរកត់សម្គាល់ថា នៅតំបន់ស្រោចស្រពពេញលេញក្នុងមួយឆ្នាំ ការធ្វើស្រូវដើមរដូវវស្សា ស្រូវវស្សា (ដោយប្រើពូជស្រូវផ្ការំដួល ផ្ការមៀត ឬពូជស្រូវក្រអូបផ្សេងទៀត) និងធ្វើបន្លែឬសណ្តែកក្នុងរដូវប្រាំង ជាប្រព័ន្ធដាំដុះផ្តល់ផលចំណេញនិងរក្សាគុណភាពដីសមស្របជាងគេ។ ម្យ៉ាងទៀត ផលិតភាពស្រូវវស្សាជាមធ្យមអាចកើនរហូតដល់៤តោន/ហត គឺច្រើនជាងផលិតភាពដែលទទួលបានជាមធ្យមក្នុងឆ្នាំ ២០១៣ ជាង១តោន ដោយកសិករត្រូវអនុវត្តតាមបង្អុំបច្ចេកទេសបង្កើនផលិតភាពរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- ការប្រើប្រាស់ជីធម្មជាតិលាយជាមួយជីគីមីតាមកម្រិតណែនាំលើដំណាំស្រូវជាការអនុវត្តប្រកបដោយនិរន្តរភាព
- ចែកពូជស្រូវផ្ការំដួល ផ្ការំដេង ផ្ការមៀត និងសែនពិដោរ ជូនកសិករ ព្រមទាំងបានបង្រៀនអំពីវិធីសាស្ត្រផលិតនិងសម្រិតសម្រាំងគ្រាប់ពូជស្រូវ
- កែច្នៃឧបករណ៍ដាំគ្រាប់ស្រូវស្ងួត បង្ហាត់បង្រៀន និងទុកជូនកសិករប្រើប្រាស់
- បើកវគ្គបណ្តុះបណ្តាលកសិករ អំពីបច្ចេកទេសដាំដុះ ថែទាំ សម្រិតសម្រាំងគ្រាប់ពូជនិងក្រោយប្រមូលផលដំណាំដែលមានកសិករចូលរួមចំនួន៨៥៥នាក់
- បានបែងចែកឯកសារ និងព្រឹត្តិបត្រព័ត៌មានកសិករជូនអ្នកពាក់ព័ន្ធ ជាពិសេសមន្ទីរកសិកម្មនិងកសិករ ចំនួន១៤.៧០០ច្បាប់
- បានបង្ហាញនូវលទ្ធផលវិភាគ DNA និងអាហារូបត្ថម្ភ (Nutrition values) របស់ពូជស្រូវផ្ការំដួល ផ្ការមៀត ផ្ការំដេង នៅក្នុងគេហទំព័ររបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ដើម្បីវិស័យឯកជនផ្នែកស្រូវអង្ករប្រើប្រាស់។

ទី៥- <u>ការគ្រប់គ្រងសម្ភារកសិកម្ម៖</u>

បច្ចុប្បន្ននេះតម្រូវការប្រើប្រាស់សម្ភារកសិកម្ម ត្រូវបានកើនឡើងជារៀងរាល់ឆ្នាំស្របតាមស្ថានភាពអភិវឌ្ឍន៍ផលិតកម្មកសិកម្មនៅក្នុងប្រទេស ដែលធ្វើឱ្យបរិមាណសម្ភារកសិកម្មនាំចូលនិងបរិមាណសម្ភារកសិកម្មដែលផលិតលាយផ្សំនៅក្នុងស្រុកត្រូវបានកើនឡើង។ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រមិនយកពន្ធ ឬកំណត់អត្រាពន្ធសូន្យលើការនាំចូលសម្ភារកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួតប្រជែងទីផ្សារសម្ភារកសិកម្មដោយស្មើភាព ដែលអាចឲ្យកសិករទិញសម្ភារកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងមានតម្លៃថោក ព្រមទាំងបានបង្កើតយន្តការអន្តរក្រសួងដើម្បីតាមដានថ្លៃសម្ភារកសិកម្មជាប្រចាំក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃសម្ភារកសិកម្ម បន្ទាបថ្លៃដើមផលិតកម្មកសិកម្ម និងបង្កឱកាសឱ្យកសិករអាចប្រកួតប្រជែងទីផ្សារកសិផលប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក និងបង្កើនការនាំចេញផងដែរ។ អង្គភាពជំនាញបានខិតខំចុះពង្រឹងការងារលើការគ្រប់-គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្មដែលបានចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(១១៣ក្រុមហ៊ុន) ព្រមទាំងពង្រឹងមូលដ្ឋានអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មនៅតាមបណ្តាខេត្ត រាជធានីឱ្យបានសមស្របតាមនីតិវិធី។ ចំពោះការងារផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹងមានសកម្មភាពដូចតទៅ៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈនាយកដ្ឋាននីតិកម្មកសិកម្មជាអង្គភាពជំនាញបានអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹង ពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម និងការប្រើប្រាស់សម្ភារកសិកម្ម នៅក្នុងខេត្តគោលដៅបានចំនួន១០ខេត្ត ដែលមានអាជីវករចូលរួមសរុបចំនួន៥៥០នាក់

- សហការអនុវត្តកម្មវិធីវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករសម្ភារកសិកម្មក្នុងឆ្នាំ២០១៤នេះ បានចំនួន ០៨ខេត្ត ត្រូវជា០៩វគ្គ ដែលមានអាជីវករចំនួន៤០៤នាក់បានចូលរួម
- បានរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មនៅបណ្តាស្រុកគោលដៅមួយចំនួនដែលមានអាជីវករចូលរួមចំនួន៥១៤នាក់
- ផ្សព្វផ្សាយអប់រំដល់ក្រុមហ៊ុនថ្នាំកសិកម្ម និងជីកសិកម្ម ស្តីពី ការអនុវត្តនីតិវិធី នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មថ្នាំកសិកម្មនិងជីកសិកម្មដែលមានអ្នកចូលរួមចំនួន១៥០នាក់
- បានចែកឯកសារសៀវភៅច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ចំនួន១.២៥០ក្បាល សៀវភៅស្តីពី បទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន១.០០០ក្បាល ព្រមទាំងខិតប័ណ្ណ និងបរិយាយប័ណ្ណផ្សព្វផ្សាយ ស្តីពីថ្នាំកសិកម្ម និងជីកសិកម្ម សរុបចំនួន១០.០០០សន្លឹក
- អង្គភាពជំនាញបានត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មចំនួន៣០ក្រុមហ៊ុន ក្នុងនោះបានអនុវត្តការពិន័យអន្តរការណ៍ចំនួន២៩ករណី ត្រូវជា១០៨.០០០.០០០រៀល ចុះត្រួតពិនិត្យដេប៉ូលក់ដុំលក់រាយសម្ភារកសិកម្មចំនួន២៣ខេត្ត ដោយក្រសួងចេញលិខិតព្រមានចំនួន០២ករណី កែតម្រូវផ្ទាល់មាត់ចំនួន ៦០ករណី និងកោះអញ្ជើញមកដោះស្រាយបទល្មើសចំនួន០៤ករណី។

គួរកត់សម្គាល់ថា ទន្ទឹមនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានចូលជាធរមាន ព្រះរាជាណាចក្រកម្ពុជាត្រូវបានយល់ព្រមឲ្យចូលរួមជាសមាជិកទី១៥១ នៃអនុសញ្ញារ៉ូថឺដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្ម គ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ" នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៣។ បច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញតួនាទីជាអាជ្ញាធរជាតិនៅក្នុងការអនុវត្តអនុសញ្ញានេះ។

ទន្ទឹមនឹងការអនុវត្តកម្មវិធីនីតិកម្មឆ្នាំ២០១៤ អង្គភាពជំនាញនីមួយៗក៏បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍបទដ្ឋានគតិយុត្ត ដែលជាកម្មវិធីនីតិកម្មវិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀងនិងការអភិវឌ្ឍផលិតកម្មកសិកម្ម រួមមាន៖ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងជីកសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ សេចក្តីព្រាងច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះព្រៃឈើ ព្រមទាំងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ បទដ្ឋានក្រោមច្បាប់រួមមានបណ្តាបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម អនុក្រឹត្យ ប្រកាស ប្រកាសរួម និងបទបញ្ជាផ្សេងទៀត ព្រមទាំងបទដ្ឋានគតិយុត្តអន្តរក្រសួងពាក់ព័ន្ធមួយចំនួនក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិបន្ថែមទៀត។

## ២. ការជំរុញពិពិធកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម

ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ដូចជា ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង មានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិងទីផ្សារផងដែរ។ ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងឧស្សាហកម្មទូទាំងប្រទេសសម្រាប់ឆ្នាំ២០១៣ សម្រេចបានប្រមាណជាង៩៤១ពាន់ហិកតា កើនលើសឆ្នាំ ២០០៩ ប្រមាណ៤០% និងបរិមាណផលសរុបប្រចាំឆ្នាំមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនឡើងបានពី៥,៤ លានតោននាឆ្នាំ២០០៩រហូតដល់ជាង១០,៥លានតោនឆ្នាំ២០១៣ កើនប្រមាណ៩៤%។

ការសម្រេចបានផ្នែកដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មក្នុងឆ្នាំ២០១៤ (គិតត្រឹមខែកញ្ញា ឆ្នាំ២០១៤) មានដូចខាងក្រោម៖

• ផ្ទៃដីដំណាំរួមផ្សំអនុវត្តបានចំនួន៦៦១.១០៨ហ.ត ស្មើនឹង១២៥,២១ភាគរយ នៃផែនការ៥២៨.០១៨ ហ.ត លើសឆ្នាំមុន៤៨.១៣៥ហ.ត

• ផ្ទៃដីដំណាំឧស្សាហកម្មអនុវត្តបានចំនួន១២១.៧០៥ហ.ត ស្មើនឹង៧៧,៥២ភាគរយនៃផែនការ១៥៧.០០៧ហ.ត តិចជាងឆ្នាំមុន១៦.៨៧៣ហ.ត។

## ៣. ការបង្កើនផលិតភាពលើដំណាំកៅស៊ូ

ក្នុងបរិបទនៃការលើកកម្ពស់ផលិតភាពដំណាំកៅស៊ូ ក្រសួងបានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រ៦ជាសំខាន់រួមមាន៖ (ទី១) ការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ (២) ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរដែលគបនឹងដំណាំកៅស៊ូ (៣) ការជំរុញការដាំដុះកៅស៊ូគ្រួសារ (៤) ការជំរុញចម្ការកៅស៊ូឧស្សាហកម្មដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ (៥) ការជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឲ្យបានល្អ (៦) ការពង្រឹងតួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូនិងអភិបាលកិច្ច។

ក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៤ ផ្ទៃដីដំណាំកៅស៊ូអនុវត្តបាន៣៣៤.០៨៤ហិកតា ធៀបនឹងចំណុចដៅប្រចាំឆ្នាំ២០១៤ ចំនួន៣៣៤.៥០៥ហិកតា គឺសម្រេចបាន៩៩,៨៧% បើធៀបនឹងផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៣មានចំនួន៣២៨.៧៧១ហិកតា គឺកើនប្រមាណ១,៦០%។ ផ្ទៃដីចៀរជ័រអនុវត្តបានចំនួន៨៨.៧៥០ហិកតា ធៀបនឹងផ្ទៃដីចៀរជ័រឆ្នាំ២០១៣ ចំនួន៧៨.៤៩៣ហិកតា គឺកើនប្រមាណ១៣,០៦%។ បរិមាណផលិតផលកៅស៊ូសម្រេចបានប្រមាណ៥២.៥០០តោន ធៀបនឹងចំណុចដៅប្រចាំឆ្នាំ២០១៤ ចំនួន១៣៧.៥២៤តោន គឺសម្រេចបានប្រមាណ៣៨,១៧% តែបើធៀបនឹងបរិមាណផលិតផលកៅស៊ូក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៣ ចំនួន៤៥.០០០តោន គឺកើនប្រមាណ១៦,៦០%។ ទិន្នផលជាមធ្យមក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៤សម្រេចបានប្រមាណ៥៩១គីឡូក្រាម/ហិកតា ស្មើនឹង៤៦,៩០%នៃចំណុចដៅប្រចាំឆ្នាំ២០១៤ដែលមានចំនួន១.២៦០គីឡូក្រាម/ហិកតា។ តែបើធៀបនឹងទិន្នផលជាមធ្យមក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៣ ដែលមានចំនួន៥៧៣គីឡូក្រាម/ហិកតា គឺកើនប្រមាណ៣%។ តាមការកត់សម្គាល់ឃើញថា ផលិតផលសម្រេចបានទាបជាងចំណុចដៅប្រចាំឆ្នាំ២០១៤ គឺដោយសារជាសមិទ្ធផលគិតត្រឹមតែ៩ខែដើមឆ្នាំនិងម្យ៉ាងទៀតបរិមាណនៃការផលិតកៅស៊ូភាគច្រើនសម្រេចបាននៅត្រីមាសទី៤។

ទោះបីជាថ្លៃកៅស៊ូមានការចុះយ៉ាងខ្លាំង និងមានកត្តាអវិជ្ជមានមួយចំនួនដែលបានជួបប្រទះកន្លងមកក៏ពិតមែនតែជារួមសមិទ្ធផលដែល សម្រេចបានគឺទៅតាមគោលដៅដែលគ្រោងទុក។ ទាំងអស់នេះ គឺកើតឡើងដោយការខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការបង្កើនលទ្ធភាព និងសមត្ថភាពក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូត្រូវតែយកចិត្តទុកដាក់ និងត្រូវជំរុញបន្ថែមទៀត ដើម្បីរួមចំណែកដោយជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

## ៤. ពិពិធកម្មកសិកម្មតាមរយៈការចិញ្ចឹមសត្វ

### ៤.១-ការកសាងផ្សព្វផ្សាយច្បាប់និងផែនការយុទ្ធសាស្ត្រ

- សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វបានប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី និងដាក់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្នុងពេលដ៏ឆាប់ខាងមុខនេះ។ ច្បាប់នេះមាន ២២ជំពូក ចំនួន១២៥មាត្រា ដោយមានសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ វាក្យស័ព្ទចំនួន ៩៣
- សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ
- បានរៀបចំត្រាបសុពេទ្យ សម្រាប់បោះ អូសត្រាលើសាច់សត្វ និងរៀបចំឯកសារសម្រាប់ចែកត្រា ដល់ភ្នាក់ងារបសុពេទ្យប្រចាំនៅសត្តឃាតដ្ឋានទូទាំងប្រទេស

- បានផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានទាក់ទងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ យ៉ាងទូលំទូលាយដល់ៈ មន្ទីរកសិកម្មរាជធានី ខេត្ត មន្ត្រីជំនាញការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត អ្នកពាក់ព័ន្ធ ជាពិសេសម្ចាស់សត្តឃាតដ្ឋាន អាជីវករពិឃាតសត្វ អង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ផលិតកម្មសត្វ ដែលនឹងត្រូវដាក់អនុវត្តឆ្នាំ២០១៥ខាងមុខនេះ។

## ៤.២-ការងារផលិតកម្មសត្វ

ស្ថិតិសត្វៈ ក្នុងនោះគោកើន១.៦០ភាគរយ ជ្រូកកើន១០.៣៣ភាគរយ បក្សីកើន១៧.៦៧ភាគរយ ប៉ុន្តែចំនួនក្របីដែលមានចំនួនតែ៦១៩.១១៤ក្បាល ថយចុះចំនួន៥.៧៦ភាគរយ (ស្ថិតិសត្វឆ្នាំ២០១៣)។

ការសាងសង់ឡជីវឧស្ម័នៈ ត្រូវបានបង្កើតឡើងតាមរយៈគម្រោងកិច្ចសហប្រតិបត្តិការចិន-កម្ពុជា និងកម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិដែលបានអនុវត្តក្នុងខេត្តចំនួន១៤បានចំនួន១៩០១ឡ ដោយគិតចាប់ពីខែសីហា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៤។

ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញចិន កម្ពុជាៈ មានពូជជ្រូកសរុប២៧៨ក្បាល ក្នុងនោះជ្រូកបាចំនួន១៣ក្បាល ជ្រូកមេ១០១ក្បាល និងកូនជ្រូក១៦៤ក្បាល។ ស្ថានីយចិញ្ចឹមជ្រូកបង្ហាញកម្ពុជា ចិន បានលក់កូនជ្រូកចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរបស់រដ្ឋ ក្នុងនោះបានលក់កូនជ្រូកជូនកសិករពីខេត្តចំនួន ១២ រួមមានខេត្តកណ្តាល ព្រះវិហារ តាកែវ ព្រះសីហនុ សៀមរាប ព្រៃវែង កំពង់ចាម រាជធានីភ្នំពេញ ពោធិ៍សាត់ បន្ទាយមានជ័យ កំពត និងរតនគិរី។

ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅៈ មានគោសរុបមានចំនួន១៨៩ក្បាល ក្នុងនោះគោបា៤ក្បាល គោមេប្រាម៉ាន់កាត់៦២ក្បាល គោជំទង់៤៩ក្បាល គោបៅដោះ៣៦ក្បាល និងគោកំផែងសែន៣៨ក្បាល។ ពូជគោមួយចំនួនត្រូវបានលក់ចែកចាយកសិករក្នុងតម្លៃគោលនយោបាយរបស់រដ្ឋ និងពូជស្មៅជាច្រើនប្រភេទដូចជាពូជស្មៅយីងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មូឡាតូ ប៉ាសប៉ាលូម និងស៊ីមួង ត្រូវបានចែកចាយផ្តល់ការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត និងកសិករ ដើម្បីធ្វើពូជដាំសម្រាប់ចំណីសត្វ។ បន្ថែមលើសពីនេះស្ថានីយក៏កំពុងផលិតមេជីវិតគោសម្រាប់ធ្វើការបង្កាត់ពូជដោយសិប្បនិម្មិត។

ភ្នាក់ងារសុខភាពសត្វភូមិៈភ្នាក់ងារសុខភាពសត្វភូមិមានចំនួន១២.៦៤៤នាក់ក្នុងនោះស្ត្រី១.១២៩នាក់ ដែលជាធនធានមនុស្សដ៏សំខាន់ ដើម្បីជំរុញការលើកកម្ពស់ការចិញ្ចឹមសត្វនៅមូលដ្ឋាន។

## ៤.៣-ការងារស្រាវជ្រាវបសុព្យាបាល

នាពេលបច្ចុប្បន្ន វិទ្យាស្ថានស្រាវជ្រាវបសុព្យាបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអង្កេត តាមដានឃ្លាំមើល សិក្សាស្រាវជ្រាវ វិភាគរកមេរោគ និងធ្វើរោគវិនិច្ឆ័យជំងឺប្រកបដោយប្រសិទ្ធភាពលើជំងឺដូចជា ជំងឺផ្តាសាយបក្សី ញូកាស មីកូប្លាស្មា ប៉េស្តជ្រូក ប្រ៊ុយសែឡូស សារទឹក អុតក្តាម សាល់ម៉ូណែឡូស ឆ្កែឆ្កួត ជ្រូកត្រចៀកខៀវ ជំងឺស្វា ជំងឺបង្កដោយប៉ារ៉ាស៊ីត។ល។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល បានប្រមូលនិងធ្វើវិភាគរកវត្តមានមេរោគបង្កជំងឺមានចំនួនសរុប ៦.៨២៦ វត្ថុវិភាគ។ ក្នុងនោះមានៈ ប៉ារ៉ាស៊ីតសាស្ត្រ បាក់តេរីសាស្ត្រ លោហិតសាស្ត្រ សេរ៉ូមសាស្ត្រ និងសរីរោគសាស្ត្រ និងមានបណ្តាញព័ត៌មានទាន់ហេតុការណ៍ដែលមានលេខ ០១២ ២១៤ ៩៧០ និង ០១២ ៨៣៣ ៧៩៥ និងទូរស័ព្ទ ៤ខ្ទង់ចំនួន២ខ្សែគឺលេខ១២៨៧ និង ១២៨៩ ដើម្បីសួរព័ត៌មានសុខភាពសត្វ ការទប់ស្កាត់ជំងឺឆ្លងសត្វ ជាពិសេស ជំងឺផ្តាសាយបក្សី។

## ៤.៤-សេវាកម្មផលិតកម្មនិងបសុព្យាបាល

ក . ការគ្រប់គ្រងសត្តឃាតដ្ឋាន

សម្រាប់ឆ្នាំ២០១៤ សត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតឲ្យបង្កើតពីអង្គភាពផលិតកម្មនិងបសុព្យាបាល មានចំនួន១៣០កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានខ្នាតអន្តរជាតិ០១កន្លែងកំពុងដំណើរការ និង០១កន្លែងទៀតកំពុងដំណើរការសាងសង់ ។ សត្វភាគច្រើនបំផុតត្រូវបានពិឃាតនៅសត្តឃាតដ្ឋានដោយមានមន្ត្រីបសុពេទ្យមានសមត្ថកិច្ចត្រួតពិនិត្យអនាម័យ សាច់ ។ អនាម័យសាច់សត្វ ម្ហូបអាហារត្រូវបានលើកកម្ពស់ដើម្បីសុខមាលភាពសាធារណៈ។

ខ . ការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ

- ក្រុមអន្តរាគមន៍ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វទូទាំងប្រទេសបានឃាត់ចាប់បទល្មើសបានចំនួន ៣១ ករណី ក្នុងនោះជ្រូក៦ករណី បក្សី៨ករណី ស៊ុត៩ករណី សាច់មាន់២ករណី សាច់ក្រួច៥ករណី ស្បែកគោ ក្របី១ករណី និងបានធ្វើការផាកពិន័យមានទឹកប្រាក់សរុប ៨៥.០០០.០០០ រៀល

- មន្ត្រីត្រួតពិនិត្យអនាម័យបក្សីនិងផលិតផលពីបក្សីត្រូវបានដាក់ឱ្យប្រចាំការនៅច្រកក្អមសំណ បាវិត ព្រៃវល្លិ ត្រពាំងផ្លុង ភ្នំដិន ពាមបន្ទារ-កោះសំពៅ តន់ហាន់ និងច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ។

គ . ការចាក់វ៉ាក់សាំង៖ ការចាក់វ៉ាក់សាំងការពារជំងឺសត្វ បានសម្រេចដូចខាងក្រោម៖

- សារទឹកគោ ក្របីសម្រេចបាន ១.០៤៩.៩០១ក្បាល
- អុតក្តាមគោ ក្របីសម្រេចបាន ៣៧.៩៤៦ក្បាល
- បូសខ្យល់លើកគោ ក្របីសម្រេចបាន ៤.៤៨៤ក្បាល។

ឃ . ជីវសុវត្ថិភាព៖ ការធ្វើជីវសុវត្ថិភាពដោយបាញ់ថ្នាំរំងាប់មេរោគបានសម្រេចចំនួន ៣.៧៦១ លើក ក្នុងនោះមាន ៖

- កន្លែងចិញ្ចឹមជ្រូកសម្រេចបាន៣១៤ លើក
- កន្លែងចិញ្ចឹមគោ ក្របីសម្រេចបាន ៣៦ លើក
- កន្លែងចិញ្ចឹមមាន់ ទាសម្រេចបាន ១.៦៧៥ លើក
- ទីផ្សារសម្រេចបាន ១១៦ លើក
- ភូមិដ្ឋានសម្រេចបាន១.១៤៥ លើក
- សត្តឃាតដ្ឋានសម្រេចបាន ៤០៦ លើក
- មធ្យោបាយដឹកជញ្ជូនសម្រេចបាន៧១ លើក។

## ៥- ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យជលផល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមានរដ្ឋបាលជលផលជាអង្គភាពជំនាញ បានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការអនុវត្តតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ដោយសម្រេចបានជោគជ័យ និងទទួលបានសមិទ្ធផលដូចខាងក្រោម៖

ក . កំណែទម្រង់វិស័យជលផល៖

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលបានលុបឡូតិ៍នេសាទចំនួន១៥៨ឡូតិ៍ ដែលមានផ្ទៃឡូត៍សរុប ៩៥៣.៧៤០ហិកតា ក្នុងនោះបានផ្តល់ជូនប្រជាពលរដ្ឋប្រើប្រាស់និងគ្រប់គ្រងតាមរយៈសហគមន៍នេសាទចំនួន៨៥៦.២៣៧ហិកតា ស្មើនឹង៨៩,៧៧% និងរក្សាទុកកន្លែងអភិរក្សជលផលចំនួន៩៧.៥០៣ហិកតា ស្មើនឹង១០,២៣%។

ខ . ការអភិវឌ្ឍន៍សហគមន៍នេសាទ៖

រហូតមកដល់ខែកញ្ញា ឆ្នាំ២០១៤នេះ សហគមន៍នេសាទចំនួន៥១៦ ត្រូវបានបង្កើតឡើង ក្នុងនោះ សហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រចំនួន៣៩។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៣៦០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រួចហើយ។ ដោយឡែក ការបង្កើតធនាគារក្តាមគិតមកដល់ខែកញ្ញា ឆ្នាំ២០១៤នេះមានចំនួន៣២កន្លែងស្មើនឹង៩៥បែ បានលែងមេក្តាមពងចំនួន៣៥.៧៦៣គក្រ ប្រមាណ២៥៩.៤៩៨ក្បាលដែលបានផ្តល់កូនក្តាមចំនួនប្រមាណ២០៧.១៦៣លានក្បាលចូលទៅក្នុងសមុទ្រវិញ។ សកម្មភាពនេះ តាមការស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍផលផលសមុទ្រឃើញថា បានធ្វើឱ្យផលក្តាមសេះមានកំណើនប្រមាណ៤ដង បើប្រៀបធៀបមុនពេលបង្កើតធនាគារក្តាម។

គ . ការអភិរក្សធនធានជលផល៖

មកទល់បច្ចុប្បន្ននេះបង្កើតជាកន្លែងអភិរក្សជលផលបានចំនួន៤៩១កន្លែង (កន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង និងសហគមន៍នេសាទ៣៦៤កន្លែង)។ មកដល់ខែកញ្ញា ក្នុងឆ្នាំ២០១៤នេះ បានបោះបង្គោលបេតុងបានចំនួន៣២ដើម និងសាងសង់ស្នាក់ការបណ្តែតទឹកបានចំនួន៤ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចខាងក្រោម៖

- អភិរក្សផ្កាថ្ម ស្មៅសមុទ្របានចំនួន៣.៨៣១ហិកតា នៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន១០០ហិកតា
- អភិរក្សអន្លង់ត្រីមេពូជបានចំនួន១៨កន្លែង នៅតំបន់មេគង្គលើ
- រៀបចំតំបន់គ្រប់គ្រងជលផលសមុទ្រគំរូចំនួន១កន្លែង មានទំហំ៤៤០.០០០ហិកតា នៅប្រជុំកោះរ៉ុង កោះរ៉ុងសន្លឹម ខេត្តព្រះសីហនុ ដើម្បីការពារធនធានជលផលនិងជីវចម្រុះ
- ចុះផ្សព្វផ្សាយពីសារៈសំខាន់នៃទីជម្រកធនធានជលផល និងប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់បានចំនួន១២វគ្គ មានប្រជាជនចូលរួមចំនួន៩០០នាក់
- បានការពារ និងអភិរក្សនូវប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់មួយចំនួនដូចជា កន្ធាយក្បាលកង្កែប ផ្សោតទឹកសាប ល្មិច អណ្តើកសរសៃ សេះសមុទ្រ ក្រពើត្រី ត្រីនាគ ត្រីគល់រាំង និងត្រីរាជ ដែលធ្វើឱ្យចំនួនរបស់វាកើនក្នុងចន្លោះពី៥ទៅ១៥ភាគរយ
- បានរៀបចំទិវាមច្ឆជាតិ០១ កក្កដា នៅអាងទឹកត្នុល ស្ថិតនៅភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានលែងកូនត្រីនិងកូនបង្កងចំនួន៥.០០០.០០០ក្បាល ទៅក្នុងបឹងធម្មជាតិ។

ឃ . ការបង្ក្រាបបទល្មើសជលផល៖

លទ្ធផលសម្រេចបានមកដល់ខែកញ្ញា ឆ្នាំ២០១៤នេះ គឺបង្ក្រាបបទល្មើសបានចំនួន១.៧៧៣ករណី (សមុទ្រ៥១ករណី) ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន១.៤៣៩ករណី ពិន័យអន្តរការណ៍ចំនួន២៤៧ករណី បញ្ជូនទៅតុលាការចំនួន៨៧ករណី ដាក់ពន្ធនាគារចំនួន១១០នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន១៧៥.០១៣.៧៥០រៀល។ វត្ថុតាងដែលបានធ្វើការរុះរើបំផ្លាញចោលនិងដកហូតឃាត់ទុកបណ្តោះអាសន្ន រួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៥០៤.៥៧១ម៉ែត្រ របាំងព្រួលប្រវែង៤.២៨១ម៉ែត្រ មងប្រវែង១៣៧.៧៤៦ម៉ែត្រ ឈ្នក់/ឆ្នុកចំនួន៤១គ្រឿង បរ/លូស្បៃមុងនិងសាច់អួនចំនួន៨.៤២៨មាត់ ឧបករណ៍ឆក់ត្រីចំនួន៤១២គ្រឿង អួនហ៊ុមចំនួន៥០វង់ លប/តុម/ឡើ/បួម/សែយឺនចំនួន២.១២២គ្រឿង សន្ទូចចំនួន៧.៨១០ផ្លែ ដាយត្រីចំនួន១៥៩មាត់ សំណាញ់/ចែវ៉ា/ជនចំនួន៦១វង់ ម៉ាញ់/នាមចំនួន៥៨វង់ អួនអូសចំនួន៣ចូរ ផ្ទុងផាងចំនួន៤មាត់ ឈ្នាងអូសចំនួន១៨គ្រឿងបង្គោល/ចម្រឹងចំនួន២៦៥.៩៤៦ដើម សម្រាស់ទំហំ១០២.៣៦០ម៉ែត្រក្រឡា កាណូត/ទូកបំពាក់ម៉ាស៊ីនចំនួន៦១គ្រឿង ទូកចំនួន២៤គ្រឿង លែងកូនត្រីប្រាម្សៅចំនួន២.៧០០.០០០ក្បាល លែងកូនត្រីឆ្តោនិងត្រីរ៉ស់ចំនួន៥៦.៤០០ក្បាល លែងកូនត្រីចម្រុះចំនួន៣.២០០.០០០ក្បាល លែងត្រីចម្រុះចូលដែនទឹកធម្មជាតិវិញចំនួន៣២.៨៨១គ.ក្រ លែងកូនក្តាមចំនួន៥០៥កូន និងលែងកូនគ្រុំ/គ្រែងឈាមចំនួន១.៥៥០គ.ក្រ។ បានប្រជុំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅតាមមូលដ្ឋានចំនួន៨៧វគ្គ អ្នកពាក់ព័ន្ធចូលរួមចំនួន៨.៨១៣នាក់ ក្នុងនោះស្ត្រីចំនួន២.១៧១នាក់។

ង . ការអភិវឌ្ឍន៍វារីវប្បកម្ម៖

មកដល់ខែកញ្ញា ឆ្នាំ២០១៤ ការអភិវឌ្ឍន៍វារីវប្បកម្មអនុវត្តបានដូចខាងក្រោម៖

- ការចិញ្ចឹមត្រីអនុវត្តបានចំនួន៧៥.០០០តោន
- ផលិតកូនត្រីពូជនិងកូនបង្កងអនុវត្តបានចំនួន១៥៥លានក្បាល
- កន្លែងភ្ញាស់ត្រីសរុបមានចំនួន ៣១០កន្លែង ដែលក្នុងនោះមាន២៩៧កន្លែង ជារបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់បច្ចេកទេសពីមន្ត្រីរដ្ឋបាលជលផល
- មានប្រជាពលរដ្ឋប្រមាណ៦៣.០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៦០នាក់ ជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅមូលដ្ឋាន
- បានផលិតខ្សែវីដេអូរបច្ចេកទេសចិញ្ចឹមត្រីចំនួន៣០០ស៊ីឌី និងផ្ទាំងរូបភាពបច្ចេកទេសចិញ្ចឹមត្រីចំនួន៦០០ផ្ទាំង សម្រាប់ផ្សព្វផ្សាយនិងចែកជូនដល់កសិករ
- បានបញ្ចប់ការងារសាងសង់វិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្ម **សម្តេចតេជោ ហ៊ុន សែន** ស្ថិតនៅឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ដែលបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅចុងខែកុម្ភៈនេះ។

ច . ការបង្កើតស្រះជម្រកត្រីសហគមន៍៖

អនុវត្តតាមអនុសាសន៍ដ៏ត្រចះត្រចង់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** កាលពីឆ្នាំ២០០៩ នៅខេត្តកែប មន្ត្រីរដ្ឋបាលជលផលគ្រប់ខេត្តបានបង្កើតស្រះជម្រកត្រីសហគមន៍បាន៨២០កន្លែង គិតរហូតដល់ខែកញ្ញា ឆ្នាំ២០១៤នេះ ហើយដែលនៅខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។ សកម្មភាពនេះ ក៏បានធ្វើឲ្យផលត្រីតាមវាលស្រែកើនឡើងប្រមាណពី៤ទៅ៦ដងផងដែរ។

ឆ . ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព៖

ជាការងារថ្មីដែលរដ្ឋបាលជលផលកំពុងពន្យល់និងផ្សព្វផ្សាយ ដើម្បីឲ្យគ្រប់កន្លែងផលិត និងកែច្នៃត្រីគោរពទៅតាមស្តង់ដាអនាម័យឲ្យបានត្រឹមត្រូវ ក្នុងន័យធានាសុខភាពសាធារណៈ និងទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាពភូមិ១ផលិតផលជលផល១ផងដែរ។ បានបង្កើតសមាគមអ្នកកែច្នៃបានចំនួន១៦ និងបានរៀបចំស្តង់ដារផលិតផលចំនួន៣ រួមមានស្តង់ដាប្រហុក ស្តង់ដារងៀតត្រីរ៉ស់ឆ្អា និងស្តង់ដារប្រឡាក់បង្កងហឹស។ រហូតមកដល់ខែកញ្ញា ឆ្នាំ២០១៤នេះ ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព អនុវត្តបានដូចខាងក្រោម៖

- បានរៀបចំសេចក្តីព្រាងគោលការណ៍ស្តីពីអនុវត្តអនាម័យល្អ (GHP)
- បានរៀបចំសេចក្តីព្រាងគោលការណ៍ស្តីពីអនុវត្តការផលិតល្អ(GMP)
- បានរៀបចំសេចក្តីព្រាងស្តីពីនីតិវិធីសម្រាប់បញ្ជាក់គុណភាពផលិតផលជលផល(តែមគុណភាព)
- បានរៀបចំនូវសេចក្តីព្រាងស្តីពីប្រព័ន្ធត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពអាហារសម្រាប់ផល ផលិតផលជលផល។

ជ . ការសិក្សាស្រាវជ្រាវ៖

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា JICA, MRC, FAO, EU, World Fish Center ជាដើម។ល។ ដែលមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវ ត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាលនិងផ្ទាំងរូបភាពជាច្រើនម៉ឺនសន្លឹក។

ញ . ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល៖

ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល១០ឆ្នាំ(២០១០-២០១៩) បានរៀបចំឡើងដោយសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីកំណែទម្រង់ជលផល ហើយត្រូវបានអនុវត្តរយៈពេល៣ឆ្នាំរួចមកហើយ។ បច្ចុប្បន្ន រដ្ឋបាលជលផលកំពុងរៀបចំធ្វើបច្ចុប្បន្នភាព កែសម្រួលដើម្បីដាក់ឱ្យអនុវត្តស្របតាមសភាពការណ៍ជាក់ស្តែង។

ដ . ស្ថិតិជលផល៖

មកដល់ខែកញ្ញា ឆ្នាំ២០១៤នេះ ផលត្រីសរុបមានចំនួន៤៨៤.០០០តោន ក្នុងនោះមាន៖

- ផលនេសាទទឹកសាប: ៣២៩.០០០តោន - ផលវារីវប្បកម្ម: ៧៥.០០០តោន
- ផលនេសាទសមុទ្រ: ៨០.០០០តោន - ការប្រមូលថវិកា ២.៦៦៦.៨២៩.២៣២រៀល។

ជារួមទោះជាជួបនៅបញ្ហាប្រឈមយ៉ាងណាក្តី ក៏រដ្ឋបាលជលផលជាសេនាធិការនៅតែខិតខំពង្រឹងស្មារតីមន្ត្រីរាជការជម្នះរាល់ឧបសគ្គក្នុងការចាត់មន្ត្រីជំនាញឲ្យចុះបង្ក្រាបបទល្មើសជាប្រចាំក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងកៀរគរថវិកាពីដៃគូដើម្បីចូលរួមធ្វើការកែទម្រង់វិស័យនេះឲ្យទទួលបានជោគជ័យតាមការរំពឹងទុក។

## ៦-ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យព្រៃឈើឆ្នាំ២០១៤៖

អនុវត្តតាមកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ រដ្ឋបាលព្រៃឈើដែលជាសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំយកចិត្តទុកដាក់បំពេញបេសកកម្មរបស់ខ្លួនក្នុងរយៈពេល០១ឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ដោយទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ដូចតទៅ៖

ក - ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍៖

ការងារបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រេចបានចំនួន៨៩២បង្គោល មានប្រវែងសរុប១០៦,១៣គីឡូម៉ែត្រគាំទ្រដោយថវិការដ្ឋនិងអង្គការJICA ស្ថិតក្នុងខេត្តកំពង់ធំ ប៉ៃលិន កំពង់ស្ពឺ តាកែវ ក្រចេះ មណ្ឌលគិរី និងខេត្តឧត្តរមានជ័យ។

ខ - សហគមន៍ព្រៃឈើ៖

រដ្ឋបាលព្រៃឈើបានដំណើរការចុះកិច្ចព្រមព្រៀងកិច្ចសហគមន៍ជាបន្តបន្ទាប់រវាងខណ្ឌរដ្ឋបាលព្រៃឈើសាមីជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើបានចំនួន៤៩សហគមន៍ គ្របដណ្តប់លើផ្ទៃដីព្រៃឈើទំហំ៥៤.៥៧៩ហិកតា ក្នុងខេត្តចំនួន៧ មានខេត្តព្រះវិហារ កំពង់ធំ កំពង់ស្ពឺ រតនគិរី មណ្ឌលគិរី កំពត និងខេត្តក្រចេះ។

គ - ការប្រមូលចំណូលពីវិស័យព្រៃឈើ៖

រដ្ឋបាលព្រៃឈើបានខិតខំប្រមូលចំណូលពីវិស័យព្រៃឈើបានចំនួន៩៦.៦៩៦,៦៨លានរៀល និង៨៥៥.៦១៧ដុល្លារក្នុងនោះចំណូលបានមកពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៥៩.៨០៧,៤៤លានរៀល ការដាក់ពិន័យលក់ឡាយឡុងនូវផល អនុផលព្រៃឈើចំនួន៣៥.៧១៨,១៣លានរៀល សេវាសាធារណៈបានចំនួន៤.០៦០,៦៤លានរៀលនិង៨៥៥.៦១៧ដុល្លារ និងថ្លៃឈ្នួលជួលដីស្ថានីយប្រេងឥន្ធនៈនិងលក់ទ្រព្យសម្បត្តិទ្រុឌទ្រោមចំនួន១១០,៤៥លានរៀល។

ឃ - ការងារដាំដើមឈើ៖

- បានបណ្តុះកូនឈើសរុបចំនួន១,៩៧លានដើម ក្នុងនោះស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ រួមជាមួយថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើបណ្តុះបានកូនឈើចំនួន១,៣លានដើម និងក្រុមហ៊ុនដៃគូផលិតពូជកូនឈើបានចំនួន៦៧៣.០០០ដើម ព្រមទាំងបានចែកចាយជូនប្រជាពលរដ្ឋចំនួនជាង២លានដើម

- បានដាំដើមឈើសរុបចំនួន២.៥៨១ហិកតា ក្នុងនោះស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋបាលព្រៃឈើដាំដើមឈើបានចំនួន៤០០ហិកតា ក្រុមហ៊ុនដៃគូដាំដើមឈើបានចំនួន៧៧១ហិកតា និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដាំបានចំនួន១.៤១០ហិកតា។

ង - ការងារស្រាវជ្រាវ និងបណ្តុះបណ្តាល៖

- បានអនុវត្តនូវគម្រោងសិក្សាស្រាវជ្រាវចំនួន០៦ រួមមាន (១) គម្រោងសិក្សាស្រាវជ្រាវពីបម្រែបម្រួលទឹកក្នុងតំបន់អាងទន្លេមេគង្គ (២) គម្រោងសិក្សាស្រាវជ្រាវអំពីវិធីសាស្រ្តស្តារព្រៃរេចរឹលសម្រាប់ការប្រើប្រាស់ច្រើនយ៉ាង (៣) គម្រោងស្រាវជ្រាវនិងស្តារព្រៃឈើឡើងវិញលើតំបន់អតីតព្រៃស្រោងនិងព្រៃល្បោះនៅខេត្តសៀមរាប (៤) គម្រោងស្រាវជ្រាវស្តីអំពីការបង្កើតប្រព័ន្ធតាមដាន ធ្វើរបាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) សម្រាប់ការអភិវឌ្ឍ យន្តការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងរេចរឹលព្រៃឈើ (៥) គម្រោងច្រករបៀងអភិរក្សជីវចម្រុះនៅមហាអនុតំបន់មេគង្គ (៦) គម្រោងសិក្សាស្រាវជ្រាវអំពីប្រភេទឈើងាយរងគ្រោះ

- សហការជាមួយដៃគូពីសាធារណរដ្ឋកូរ៉េ ដើម្បីសាងសង់អគារវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃមួយដែលមានកម្ពស់ពីរជាន់នៅភ្នំពេញ និងស្ថានីយស្រាវជ្រាវមួយកន្លែងទៀតនៅខេត្តសៀមរាបដែលអគារទាំងពីរនេះជួយបង្កលក្ខណៈងាយស្រួលដល់ការសិក្សាបច្ចេកទេសព្រៃឈើ

- សហការជាមួយដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងគ្រឹះស្ថានសិក្សាអប់រំមួយចំនួនទាំងក្នុងនិងក្រៅប្រទេសក្នុងការរៀបចំ និងបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាមួយចំនួនដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសក៏ដូចជាផ្លាស់ប្តូរនូវចំណេះដឹងក្នុងវិស័យព្រៃឈើព្រមទាំងបានធ្វើការទំនាក់ទំនង និងរៀបចំបញ្ជូនមន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ និងមន្ត្រីពីអង្គភាពក្រោមរដ្ឋបាលព្រៃឈើទៅសិក្សានៅក្រៅប្រទេស។

ច - ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ៖

- ចាប់ឃាត់និងរឹបអូសឈើ គ្រប់ប្រភេទសរុបចំនួន២.៣៦៧ករណី ស្មើនឹង៦.៩៤៧ម$^{3}$២៨៩ សត្វព្រៃរស់-ងាប់ចំនួន៩៨៥ក្បាល និង១.៦៩៣គីឡូក្រាម រថយន្តនិងគ្រឿងចក្រគ្រប់ប្រភេទចំនួន១.៥២១គ្រឿង រួមជាមួយអនុផលព្រៃឈើនិងសម្ភារផ្សេងៗមួយចំនួនទៀត។ ចំពោះសំណុំរឿងបទល្មើសព្រៃឈើសត្វព្រៃដែលត្រូវធ្វើការពិន័យអន្តរការណ៍មានចំនួន៥០៣ករណី និងសំណុំរឿងបទល្មើសព្រៃឈើគ្រប់ប្រភេទដែលត្រូវបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្តមានចំនួន១.៨៦៤ករណី និងចាប់ឃាត់ខ្លួនជនល្មើសដោយធ្វើការរំលោភនាំ និងបញ្ជូនទៅតុលាការដើម្បីធ្វើការផ្តន្ទាទោសតាមនីតិវិធីច្បាប់ចំនួន៧នាក់

- រាល់បទល្មើសព្រៃឈើដែលបានបង្ក្រាបរួច ត្រូវបានរដ្ឋបាលព្រៃឈើដាក់បញ្ចូលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាននៅតាមបណ្តាខេត្តមានចំនួនសរុប២.៥១៣ហិកតា ចេញដីកាប្រកាសបដិសេធដកហូតដីព្រៃឈើដែលបានរំលោភបំពានមកទុកជាសម្បត្តិរដ្ឋវិញចំនួន ៨៣១ហិកតា និងដកហូតរណារយន្តបានចំនួន១០១គ្រឿង។

ជ - ការងារអភិរក្សព្រៃឈើ និងសត្វព្រៃ៖

- បានអភិរក្សតំបន់ព្រៃការពារទំហំ១៦.២៨០ហិកតា ដើម្បីការពារធនធានព្រៃឈើ និងជីវចម្រុះ ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន តាមរយៈការប្រមូលផល អនុផលព្រៃឈើ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងរួមចំណែកដល់ការធ្វើនិយតកម្មប្រភពទឹកសម្រាប់វារីអគ្គិសនីដែលមានលទ្ធភាពផលិតចំនួនជិត១.០០០មេហ្គាវ៉ាត់នៅតំបន់ជួរភ្នំក្រវាញដើម្បីជួយលើកកម្ពស់កំណើនសេដ្ឋកិច្ចនិងបរិស្ថានដល់សាធារណជន ទឹកសាបសម្រាប់ប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្ម

- បានបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែងដែលមានផ្ទៃដីទំហំ៦៦.៩៣២ហិកតាដើម្បីអភិរក្សសត្វព្រៃសំខាន់ៗ ជាពិសេសក្រុមប្រភេទមានដោយកម្រ និងជិតផុត

ពូជ។ រៀបចំតំបន់សម្រាកលំហែទស្សនាចរណ៍កំសាន្ត០២កន្លែងនៅក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃដើម្បីលើកស្ទួយវិស័យទេសចរណ៍ និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ការអភិវឌ្ឍសហគមន៍ និងជួយដល់ការគ្រប់គ្រង និងអភិរក្សជីវចម្រុះដោយប្រសិទ្ធភាព

- បានថែរក្សាការពារសត្វព្រៃគ្រប់ប្រភេទចំនួន១.២២៤ក្បាល (បក្សី៤៨ប្រភេទ ថនិកសត្វ៣៨ប្រភេទនិងល្មូន ១១ប្រភេទ) សង្គ្រោះសត្វព្រៃគ្រប់ប្រភេទចំនួន៩៥៤ក្បាល ស្តារលទ្ធភាពជីវសាស្ត្រ និងការដោះលែងទៅព្រៃធម្មជាតិវិញ ចំនួន៨៧០ក្បាលព្យាបាលសត្វព្រៃរបួស ឈឺ ពិការចំនួន៣០០ក្បាល ធ្វើការអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្ស និស្សិតក្នុងនិងក្រៅប្រទេសបានចំនួន៨.៥៥០នាក់ បណ្តុះនិងដាំកូនឈើចំនួន១៨.២៥០ដើម សាងសង់សំណង់ទ្រុងសត្វ និងសំណង់ផ្សេងៗបានជាច្រើនទៀត

-បានអភិរក្សតំបន់ដែនជម្រកសត្វក្រពើសំខាន់ៗចំនួន០៤កន្លែងគឺនៅខេត្តកោះកុង (តំបន់អារ៉ែង ឆាយរាប តំបន់ស្តារក្រពើក្នុងឃុំតាតៃលើ) និងនៅខេត្តពោធិ៍សាត់ (តំបន់អូរសោម) និងបានដោះលែងក្រពើភ្នំចំនួន២៨ក្បាលចូលបឹងធម្មជាតិនៅក្នុងខេត្តកោះកុងព្រមទាំងបានបំពាក់ឧបករណ៍វិទ្យុសម្លេងតាមដានសត្វក្រពើ ដែលបានដោះលែងចំនួន .១៥ក្បាល។

ឈ-ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម៖

- មានរោងចក្រកែច្នៃឈើ រោងម៉ាស៊ីនអារឈើ រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ មធ្យម តូច សរុបចំនួន៤០៨កន្លែង ដើម្បីកែច្នៃផល អនុផលព្រៃឈើស្របច្បាប់សម្រាប់សេចក្តីត្រូវការប្រើប្រាស់ក្នុងស្រុក និងធ្វើការនាំចេញតាមការចាំបាច់ និងមានរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើទូទាំងប្រទេសសរុបមានចំនួន ៦២៧កន្លែង

- មានក្រុមហ៊ុនចំនួន០៦ បាននាំចេញទៅបរទេសនូវឈើកែច្នៃគ្រប់ប្រភេទចំនួន ៧៤.២៨៣ម៉ែត្រគ្រីគុណ ឈើអាកាស្យាកាត់កង់ៗចំនួន៥០០ស្ទែរ និងធ្យូងអាកាស្យាចំនួន៣២តោន និងមានក្រុមហ៊ុនចំនួន០១ បាននាំចូលឈើអារនិងឈើឡាំងប្រភេទCHANFUTA ចំនួន១.៣០០ម៉ែត្រគ្រីគុណ។

ញ- ការងារសហប្រតិបត្តិការអន្តរជាតិ៖

ដៃគូអភិវឌ្ឍន៍ដែលគាំទ្រដល់កម្មវិធីព្រៃឈើជាតិមានចំនួន១១ ស្មើនឹង៤៨គម្រោង មានថវិកាសរុបចំនួន ១៧លានដុល្លារអាមេរិក អង្គការមិនមែនរដ្ឋាភិបាលមានចំនួន១២ មានថវិកាសរុបចំនួន៣,២៤លានដុល្លារអាមេរិក សម្រាប់អនុវត្ត១៦គម្រោង រាជរដ្ឋាភិបាលកម្ពុជាមានចំនួន០៦គម្រោង មានថវិកាសរុបចំនួន១,២៧លានដុល្លារអាមេរិក។

ដើម្បីជាដំណោះស្រាយលើបញ្ហាប្រឈមដែលអង្គភាពរដ្ឋបាលព្រៃឈើបាន និងកំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទយល់ឃើញថាការចូលរួមយ៉ាងជិតស្និទ្ធពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តជាធរមានពិសេសបទបញ្ជាដ៏ម៉ឺងម៉ាត់របស់ប្រមុខដ៏ឆ្នើមនៃរាជរដ្ឋាភិបាល គឺជាកត្តាជ័យជំនះក្នុងការជួយពង្រឹងស្មារតីសមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើដើម្បីគាំទ្រដល់កម្មវិធីកំណែទម្រង់វិស័យព្រៃឈើឱ្យទទួលបានជោគជ័យ។

## ៧-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវទិសដៅជាយុទ្ធសាស្រ្ត នៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០ ដើម្បីផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមធ្យោបាយទៅរកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្មនិងវិមជ្ឈការ។ ផ្អែកតាមទិសដៅនៃកម្មវិធីកំណែទម្រង់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាក្រសួងមួយក្នុងចំណោមក្រសួង១០ ដែលត្រូវបានដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញ ដោយមានការវិភាជថវិកា និងការគ្រោងផ្ទេរប្រតិភូកម្មសិទ្ធិអំណាច ក្នុងការអនុវត្តចំណាយថវិកាដល់បណ្តាអង្គភាពថវិកាមួយចំនួនដែលនឹងគ្រោងបង្កើតឡើងនាពេលខាងមុខនេះ។ ផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ត្រូវបានរៀបចំស្របតាមខ្លឹមសារនៃសារាចរណែនាំលេខ០២សរណន ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៥ និងបានគ្របដណ្តប់ថវិកាទាំង

អង្គភាពបច្ចេកទេសថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត។ ដើម្បីពង្រឹងសកម្មភាពខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានសម្រេចនូវសកម្មភាពជាអាទិភាពដូចខាងក្រោម៖

ក- បានរៀបចំបង្កើតអង្គភាពថវិកាទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្តដោយបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយព្រមទាំងបានពង្រឹងសមត្ថភាពមន្ត្រីគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការគ្រប់គ្រងថវិកានិងការអនុវត្តថវិកាទាំងថវិកាតាមកម្មវិធី និងមិនមែនតាមកម្មវិធី។

ខ- កំពុងរៀបចំប្រព័ន្ធតាមដានវាយតម្លៃតាមកុំព្យូទ័រដើម្បីឱ្យសង្គតិភាពទៅនឹងការវិវឌ្ឍន៍នៃការគ្រប់គ្រង និងការអនុវត្តថវិកាតាមកម្មវិធីពេញលេញ។

គ- ការគ្រប់គ្រងគណនេយ្យតាមកុំព្យូទ័រដែលជាឆ្នាប់ផ្សារភ្ជាប់ទៅនឹងប្រព័ន្ធ FMIS របស់រាជរដ្ឋាភិបាល។

ឃ- មន្ត្រីជំនាញបានចូលរួមទស្សនកិច្ចសិក្សានៅប្រទេសញ៉ូហ្សេឡែន ដើម្បីជាបទពិសោធន៍ក្នុងការរៀបចំគោលនយោបាយថវិកា ការអនុវត្តថវិកាប្រកបដោយតម្លាភាពទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។

ង- ការងារប្រមូលចំណូលថវិការដ្ឋ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំតាមគ្រប់រូបភាពដើម្បីប្រមូលចំណូលបង់ចូលថវិកាជាតិដែលមានវឌ្ឍនភាពដូចតទៅ៖ ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ ចំណូលត្រូវប្រមូលឱ្យបានចំនួន៤៩.៨១០.០០០.០០០រៀល ជាក់ស្តែង ចំណូលថវិការដ្ឋគិតត្រឹមខែកញ្ញា ឆ្នាំ២០១៤ ប្រមូលបានចំនួន ៦២.៤៩៦.២៩០.០១៥រៀល មានការកើនឡើងចំនួន១២.៦៨៦.២៩០.០១៥រៀល. បើធៀបនឹងរយៈពេល៩ខែដូចគ្នានៅឆ្នាំ២០១៣ ប្រមូលបានចំណូលចំនួន៤៥.៥៥៧.៣២០.២៩៦រៀល គឺមានការកើនឡើងចំនួន១៦.៦៣៨.៩៦៩.៧១៩រៀល។

ជារួមផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកសាងឲ្យមានសង្គតិភាពជាមួយគោលនយោបាយខាងលើ ដែលអាចជាមូលដ្ឋានសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្ត "ថវិកាកម្មវិធីពេញលេញ" ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

**៨ - ការងារសហប្រតិបត្តិការអន្តរជាតិ**

-ក្នុងកិច្ចប្រជុំលើកទី១៤របស់រដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានបូក៣នៅប្រទេសភូមានាពេលថ្មីៗ នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលសិទ្ធប្រទានពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខាលើ៖ ១-អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការស្បៀងនិងកសិកម្ម ២-អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការអាស៊ាន និងអភិក្រមចម្រុះក្នុងការជំរុញផលិតផលកសិកម្ម និងព្រៃឈើ និង៣-អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនាម័យ និងភូតគាមអនាម័យ

-ធ្វើជាម្ចាស់ផ្ទះសម្រាប់រៀបចំកិច្ចប្រជុំអាស៊ាន ៖ (១) កិច្ចប្រជុំលើកទី១០ នៃក្រុមការងារបមាណីអាស៊ានស្តីពីផលិតផលសាកវប្បកម្ម និងកិច្ចប្រជុំពាក់ព័ន្ធ (២) កិច្ចប្រជុំលើទី១៦ នៃក្រុមការងារជំនាញការ និងលើកទី២១ នៃក្រុមការងារដំណាំអាស៊ាន (៣) កិច្ចប្រជុំលើកទី១៧ នៃឧត្តមមន្ត្រីព្រៃឈើអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ

-រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដើម្បីសុំការអនុញ្ញាតគាំទ្រគោលនយោបាយស្តីពីការនេសាទបាឡែនប្រកបដោយនិរន្តរភាពរបស់ប្រទេសជប៉ុន

-ថ្នាក់ដឹកនាំក្រសួងបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងគណៈកម្មាធិការចម្រុះកម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ

-ថ្នាក់ដឹកនាំក្រសួងបានទទួលជួបសវនាការជាបន្តបន្ទាប់ជាមួយតំណាងស្ថានទូតនានា អង្គការជាតិ-អន្តរជាតិ និងវិស័យឯកជនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្មារតីទទួលខុសត្រូវ

-សម្របសម្រួលរៀបចំបែបបទ និងគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន៥៤រូប នៅក្នុងប្រទេសចំនួន១០។

-ក្នុងការចូលរួមគាំទ្រនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ប្រទេសផ្តល់ជំនួយក៏ដូចជាដៃគូអភិវឌ្ឍអន្តរជាតិនានាដូចជា EU ADB IFAD JICA USAID World Bank FAO AFD អូស្ត្រាលី ហ្វាំងឡង់ ....។ល។ បានផ្តល់នូវហិរញ្ញប្បទានជាច្រើន រួមទាំងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលផងដែរចូលរួមលើកកម្ពស់យ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យកសិកម្ម ពិសេសការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនិងជំរុញកសិពាណិជ្ជូបនីយកម្ម។

### ៩ - ការងារផែនការ គោលនយោបាយសម្រាប់អភិវឌ្ឍកសិកម្ម ២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរុក្ខាប្រមាញ់ និងនេសាទ២០១៤-២០១៨ បានរៀបចំស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ ការកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ៖

ទិសដៅគោលនយោបាយរួម (Overall Policy Goal) ៖ "ជំរុញកំណើនកសិកម្មឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារនិងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព"។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតកម្មវិធីថ្មីចំនួន៥ ដូចខាងក្រោមនេះ៖

<u>កម្មវិធីទី-១៖ បង្កើនផលិតភាព ពិពិធកម្មកសិកម្មនិងពាណិជ្ជូបនីយកម្មកសិកម្ម</u>

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន២០និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

<u>កម្មវិធីទី-២៖ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ</u>

ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣ភាគរយក្នុងមួយឆ្នាំ ដោយផ្តោតលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវនិងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ សាច់សត្វប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៩។

<u>កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព</u>

បង្កើនការការពារធនធានជលផល បង្កើតតំបន់អភិរក្ស លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ធានាឱ្យបាននូវផ្ទៃនេសាទសម្រាប់សហគមន៍នេសាទ និងបង្កើនផលិតកម្មនេសាទ លើមូលដ្ឋានជំរុញវារីវប្បកម្មក្នុងរង្វង់១៥%ក្នុងមួយឆ្នាំ និងពង្រឹងសមត្ថភាពនេសាទជារៀងរាល់ឆ្នាំ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១១។

<u>កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព</u>

បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ ជំរុញការដាំឈើ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានជាអតិបរមាក្នុង១ឆ្នាំ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៨។

កម្មវិធីទី-៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១២ និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

## III-សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលពេញមួយឆ្នាំគិតពីខែកញ្ញាឆ្នាំ២០១៣ដល់ខែកញ្ញាឆ្នាំ២០១៤ ដែលជាខួបមួយឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា យើងអាចវាយតម្លៃជារួមថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិរួមមានកង្វះខាតទឹក គ្រោះជំនន់ទឹកភ្លៀងរដូវវស្សា ការបំផ្លាញដោយសត្វល្អិតចង្រៃ តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើបានធ្វើឱ្យផលិតកម្មកសិកម្ម មានការរីកចម្រើនគួរឱ្យកត់សម្គាល់។

ជារួមផលិតកម្មដំណាំ ពិសេសដំណាំស្រូវតាមការកត់សម្គាល់ឃើញថា បានទទួលលទ្ធផលគួរជាទីពេញចិត្ត ហើយអាចសល់ស្បៀង (ជាអង្ករ) សរុបចំនួនជាង៣លានតោន (ឬ៤,៨លានតោនស្រូវ) នៅឆ្នាំ២០១៣ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។ សម្រាប់ឆ្នាំ២០១៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រោងនឹងធ្វើការវាយតម្លៃអំពីលទ្ធផលនៃការងារបង្កបង្កើនផលដំណាំស្រូវវស្សា ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។ ជារួមកត្តាកើនឡើងនៃទិន្នផលផលិតកម្មកសិកម្មកម្ពុជា ពិសេសផលិតកម្មស្រូវពីមួយឆ្នាំទៅមួយឆ្នាំ មានការវិវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺ (១) ការពង្រីកផ្ទៃដីដាំដុះ ដែលរួមទាំងការធ្វើបង្កើនរដូវនិងប្រពលវប្បកម្ម (២) សមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពូជថ្មី បច្ចេកទេសដាំដុះសមស្រប ការថែទាំប្រកបដោយប្រសិទ្ធភាព ពិសេសការកែប្រែទម្លាប់របស់ប្រជាកសិករ។

ដំណាំឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ ជាក់ស្តែង ផ្ទៃដីដាំដុះកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារ មានការវិវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ផលិតកម្មសត្វ គោ ក្របី ជ្រូក មាន់ ទា មានការវិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារការបង្កើនការងារផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វដល់ប្រជាកសិករបានទូលាយជាងមុន។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល ពិសេសកំណែទម្រង់ក្នុងវិស័យទាំងពីរនេះ កំពុងស្ថិតនៅតែជាប្រធានបទតឹងតែង ស្មុគស្មាញ ហើយដែលត្រូវតែខិតខំបន្តសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានារួមទាំងវិស័យឯកជនផងដែរក៏កំពុងត្រូវបានពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់រួមទាំងការអភិវឌ្ឍន៍ធនធានមនុស្សដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលងបានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការលើកកម្ពស់ ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ក៏ត្រូវបានពង្រឹងក្នុងស្មារតី

យកចិត្តទុកដាក់ខ្ពស់និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ លើសពីនេះទៅទៀត ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាលពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ គ្រប់ផ្នែកទាំងអស់ក៏មិនដែលមើលរំលងអំពីការចូលរួមយ៉ាងសកម្មរបស់កិច្ចការយេនឌ័រផងដែរ។ ទន្ទឹមនឹងនេះ អង្គភាពជំនាញនីមួយៗជាសេនាធិការនឹងបន្តអនុវត្តតាមទិសដៅ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះសម្រាប់ឆ្នាំ២០១៤-២០១៥ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។ តែទោះយ៉ាងណាក្តី ផ្លូវនៅវែងឆ្ងាយទៀត ដើម្បីសម្រេចបានគោលដៅ និងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមួយតាមលក្ខណៈវិទ្យាសាស្ត្រទំនើប និងមានប្រសិទ្ធភាពខ្ពស់។ ជាពិសេសការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិតាមទិសដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ក៏ដូចជាក្នុងបរិបទនៃសកលភាវូបនីយកម្ម ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**